# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ៧៦៨

ចុះថ្ងៃទី០៨-០៨-២០១២

សាលដីកា

លេខ : ៨៧ ក្រIV "វ"

ចុះថ្ងៃទី ១៨-០៩-២០១៤

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ : នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦-០៧-២០១៤ បានបើកសវនាការជាសាធារណៈ នៅសាលាឧទ្ធរណ៍ នាថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៤ ដោយមាន ៖

### សមាសភាពក្រុមប្រឹក្សា

លោក [redacted] ជាប្រធានក្រុមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

### តំណាងមហាអយ្យការ

ឯកឧត្តម [redacted] ជាអគ្គព្រះរាជអាជ្ញារង

### ក្រឡាបញ្ជី

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃសំណុំរឿងព្រហ្មទណ្ឌលេខ : ៧៦៨ ចុះថ្ងៃទី០៨-០៨-២០១២ ដែលមាន ៖

១- ជនជាប់ចោទឈ្មោះ [redacted] រតនា ហៅ មករា ភេទប្រុស អាយុ២៦ឆ្នាំ ជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើតសង្កាត់ [redacted] ទីលំនៅបច្ចុប្បន្នមិនពិតប្រាកដ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "ស" នៅលីវ ទោសពីមុនធ្លាប់ជាប់ពន្ធនាគារចំនួន ០៨ខែ ពីបទ លួច ជានីតិជន ។ ឃុំថ្ងៃទី០៥-០១-២០១២ ។

២- ជនជាប់ចោទឈ្មោះ [redacted] យី ហៅ យី (ប្តឹងឧទ្ធរណ៍) ភេទប្រុស អាយុ២៨ឆ្នាំ ជាតិខ្មែរ មុខរបរគ្មាន ទីកន្លែងកំណើតភូមិ [redacted] ទីលំនៅបច្ចុប្បន្ន មិនពិតប្រាកដ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "រ" ទោសពីមុនធ្លាប់ជាប់ពន្ធនាគារខេត្តព្រៃវែង ០៦ខែ ពីបទបង្ករបួសស្នាម ជានីតិជន ។ ឃុំខ្លួនថ្ងៃទី០៩-០១-២០១២ ។

មានលោក [redacted] ចន្ថា ជាមេធាវីការពារសិទ្ធិ ។

ជាប់ចោទពីបទ : ឃាតកម្ម ប្រព្រឹត្តនៅចំណុចសួនច្បារវិមានឯករាជ្យ ផ្លូវព្រះសីហនុ ភូមិទី៣ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០១-០១-២០១២ បទល្មើសព្រហ្មទណ្ឌ មានចែងឲ្យផ្តន្ទាទោសតាមមាត្រា១៩៩ នៃក្រមព្រហ្មទណ្ឌ ។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទស្រី អាយុ២៣ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅ [redacted] ។

ឯរឿងហេតុមានដូចតទៅ ៖

កាលពីថ្ងៃទី០១-០១-២០១២ វេលាម៉ោង០១ និង២០នាទី ឈ្មោះ [redacted] លីដា ភេទប្រុស អាយុ២១ឆ្នាំ និងមិត្តស្រីឈ្មោះ [redacted] វល័ក្ខ ភេទស្រី អាយុ២៣ឆ្នាំ បាននាំគ្នាដើរលេងបុណ្យឆ្លងឆ្នាំសកលនៅមុំសួនច្បារវិមានឯករាជ្យ ដែលស្ថិតនៅលើផ្លូវព្រះសីហនុ ភូមិទី៣ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ស្រាប់តែឈ្មោះ [redacted] រតនា ភេទប្រុស អាយុ២៦ឆ្នាំ និងឈ្មោះ [redacted] យី ភេទប្រុស អាយុ២៧ឆ្នាំ មានសភាពស្រវឹងស្រា បានដើរទៅប៉ះមិត្តស្រីរបស់ឈ្មោះ [redacted] លីដា គឺឈ្មោះ [redacted] វល័ក្ខ ហើយក៏បាននិយាយខឹងង និងទាស់ពាក្យសំដីគ្នាខ្លាំងៗ រហូតឈានដល់ការប្រតាយប្រតប់គ្នាទៅវិញទៅមក នៅពេលនោះឈ្មោះ [redacted] យី បានរើសដុំថ្មគប់ទៅលើឈ្មោះ [redacted] លីដា ត្រូវចំខ្លួន បន្ទាប់មកឈ្មោះ [redacted] លីដា បានដកខ្សែក្រវ៉ាត់ដេញវាយទៅលើឈ្មោះ [redacted] រតនា និងឈ្មោះ [redacted] យី វិញ ហើយនៅពេលនោះឈ្មោះ [redacted] រតនា បានយកកូនកាំបិតទៅចាក់លើឈ្មោះ [redacted] លីដា ត្រូវចំដើមទ្រូងខាងឆ្វេងបណ្តាលឲ្យដួលស្លាប់បាត់បង់ជីវិតនៅកន្លែងកើតហេតុតែម្តង ។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៤៩ កបព "ទ" ចុះថ្ងៃទី១១-០៦-២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ បានសម្រេចសេចក្តីមានខ្លឹមសារថា :

១- ផ្តន្ទាទោសឈ្មោះ [redacted] រតនា ហៅ មករា ភេទប្រុស អាយុ២៦ឆ្នាំ និងឈ្មោះ [redacted] យី ហៅ យី ភេទប្រុស អាយុ២៧ឆ្នាំ ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់រយៈពេល ១១ (ដប់មួយ)ឆ្នាំ ពីបទ ឃាតកម្ម ប្រព្រឹត្តនៅចំណុចសួនច្បារវិមានឯករាជ្យ ផ្លូវព្រះសីហនុ ភូមិទី៣ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០១-០១-២០១២ តាមបញ្ញត្តិមាត្រា១៩៩ នៃក្រមព្រហ្មទណ្ឌ ។

២- ឲ្យឈ្មោះ [redacted] រតនា ហៅ មករា និងឈ្មោះ [redacted] យី ហៅ យី រួមគ្នាសងសំណងការខូចខាត និងជម្ងឺចិត្តឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចំនួន ១៥,០០០,០០០ (ដប់ប្រាំលាន)រៀល ការទាមទារលើសពីនេះ ត្រូវច្រានចោល ។

១៤៩

សាលក្រមនេះ ជំនុំជម្រះនៅថ្ងៃទី២៣-០៥-២០១២ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១១-០៦-២០១២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] រតនា ហៅ មករា និងឈ្មោះ [redacted] យី កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] វល័ក្ខ ។

បើកសិទ្ធិប្តឹងទាស់ និងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

បានឃើញ ពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៩-០៧-២០១២ របស់ជនជាប់ចោទឈ្មោះ [redacted] យី ប្តឹងឧទ្ធរណ៍ទឹងសាលក្រមព្រហ្មទណ្ឌលេខ ៤៩ កបព “ទ” ចុះថ្ងៃទី១១-០៦-២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់សេចក្តីសម្រេចទាំងមូល ។

បានឃើញ របាយការណ៍រឿងរបស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ ចុះថ្ងៃទី១៣-១១-២០១៤ ។

បានឃើញ សេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ចុះថ្ងៃទី១២-០២-២០១៣ ។

## នាពេលសវនាការ

- ប្រធានក្រុមប្រឹក្សាអានរបាយការណ៍សង្ខេបរឿងក្តី

- អំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] យី: កាលពីថ្ងៃទី០១-០១-២០១២ វេលាម៉ោងប្រហែល ១ អាធ្រាត្របន្ទាប់ពីផឹកស្រាជាមួយមិត្តភក្តិឈ្មោះ [redacted] រតនា ហៅ មករា ។ ពួកខ្លួនបានដើរលេងនៅម្តុំសួនវិមានឯករាជ្យ ក៏បានជួបជាមួយនឹងជនរងគ្រោះ នៅម្តុំនាគបាញ់ទឹក កំពុងដើរជាមួយសង្សាគាត់ ។ ខ្លួនបានដើរប៉ះស្មាសង្សារបស់ជនរងគ្រោះ ដោយសារពេលនោះមានមនុស្សច្រើនពេក ។ ពេលនោះជនរងគ្រោះក៏ប្រើពាក្យសំដីខឹងងដាក់ពួកខ្លួន ហើយក៏មានការឈ្លោះប្រកែកគ្នា ហើយជនរងគ្រោះក៏វាយខ្លួនដោយដៃ ហើយខ្លួនក៏វាយបកទៅវិញ ។ ខ្លួនបានយកដុំថ្មគប់ទៅលើជនរងគ្រោះ ចំណែកជនរងគ្រោះក៏យកខ្សែក្រវ៉ាត់របស់គេ ដេញវាយខ្លួន ពេលនោះឈ្មោះ [redacted] រតនា ហៅ មករា ក៏បានរត់មកជួយខ្លួន ហើយយកកូនកាំបិតនៅនឹងខ្លួនវា ចាក់ទៅលើជនរងគ្រោះមួយកាំបិត ប៉ុន្តែខ្លួនពុំ បានដឹងថាត្រូវចំកន្លែងណានោះទេ ។ កាំបិតដែលឈ្មោះ [redacted] រតនា ហៅ មករា ប្រើគឺជាកាំបិតឡាម ។ ពេលនោះឈ្មោះ [redacted] រតនា ចាក់ហើយជនរងគ្រោះក៏ដួល ហើយពួកខ្លួនក៏រត់គេចខ្លួនចេញពីហ្វូងមនុស្ស សំដៅទៅមុខវត្តបុទុម ជិតហង្ស (រូបសំណាក់ហង្ស) ។ រហូតដល់ម៉ោង ៥ ល្ងាច សមត្ថកិច្ចក៏ឃាត់ពួកខ្លួន នៅម្តុំដីឡូត៍បឹងត្របែក ។ ខ្លួនពុំមានចេតនាសម្លាប់ជនរងគ្រោះ ឬក៏សង្សារជនរងគ្រោះនោះទេហើយក៏ពុំដែលមានគំនុំអ្វីពីមុនមកដែរ ។ ខ្លួនសំណូមពរឱ្យតុលាការបន្ធូរបន្ថយទោសឱ្យខ្លួន ។

- អំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] រតនា : កាលពីថ្ងៃទី០១-០១-២០១២ វេលាម៉ោងប្រហែល ៧ និងសូន្យនាទី ពួកខ្លួនក៏បានបបួលគ្នាទិញស្រាផឹក នៅចំណុចនាគបាញ់ទឹក ពួកខ្លួនទាំងពីរនាក់អង្គុយផឹកស្រាអស់ចំនួន ២ ដប រហូតដល់ចប់កម្មវិធី បាញ់កាំជ្រួចឆ្លងឆ្នាំថ្មី២០១២ ។ ពួកខ្លួនផឹកស្រារួចនាំគ្នាទៅមើលគេច្រៀងនៅសួនច្បារមុខកាស៊ីណូណាហ្គា ។ ពេលពួកខ្លួនដើរបានបន្តិចក៏ប៉ះជនរងគ្រោះពីរនាក់ គឺប៉ះមនុស្សស្រី ។ ពេលប៉ះនោះ គឺខ្លួនមិនបានប៉ះទេ គឺឈ្មោះ [redacted] យី ក៏មានការប៉ះទង្គិចគ្នា ឈ្លោះ

ប្រកែកគ្នា ។ ពេលនោះជនរងគ្រោះ ក៏បានហក់ធាក់ឈ្មោះ [redacted] យី ហើយឈ្មោះ [redacted] យី ក៏ខឹង ក៏រើសដុំថ្មគប់ទៅលើជនរងគ្រោះ មួយដុំត្រូវចំខ្លួន ពេលនោះជនរងគ្រោះក៏បានហូតខ្សែក្រវ៉ាត់ ចេញពីចង្កេះស្ទុះមកវ៉ៃពួកខ្លួន ចំណែកពួកខ្លួនដែលកាន់កូនកាំបិត ពេលនោះជនរងគ្រោះក៏បានស្ទុះសំដៅធាក់ខ្លួនមួយជើង ពេលនោះខ្លួនក៏បានចាក់ជនរងគ្រោះមួយកូនកាំបិតត្រូវចំដើមទ្រូងដួលលើឥដ្ឋ ។ ពេលនោះខ្លួន នឹងឈ្មោះ [redacted] យី ក៏បានរត់គេចខ្លួនក្បែរហាងលើស្ពានមុខវត្តបុទុមវត្តី រហូតដល់ម៉ោងប្រហែល ប្រាំបីព្រឹកថ្ងៃទី០១-០១-២០១២ ពួកខ្លួនទាំងពីរនាក់ក៏បាននាំគ្នាជិះម៉ូតូឌុបមកដីឡូត៍ នៅម្តុំបឹងត្របែក រហូតដល់ម៉ោង៥ ល្ងាច ថ្ងៃទី០១-០១-២០១២ សមត្ថកិច្ចចុះទៅឃាត់ខ្លួន ខ្លួន និងឈ្មោះ [redacted] យី នាំមកធ្វើ ការសាកសួរ ហើយក៏ឃាត់ខ្លួនតែម្តង ។ កាំបិតនោះខ្លួនរើសបានតាមផ្លូវ ហើយខ្លួនពិតជាបានចាក់ជនរងគ្រោះមែន ។ ខ្លួនសំណូមពរឱ្យតុលាការបន្ធូរបន្ថយទោសឱ្យខ្លួន ព្រោះខ្លួនដឹងកំហុសហើយ ។

- អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] កាលពីថ្ងៃទី០១-០១-២០១២ ប្រហែលជាម៉ោង ១ អាធ្រាត្រ ខ្លួន និងសង្សារឈ្មោះ [redacted] លីដា បាននាំគ្នាដើរលេង នៅចំណុចទាគបាញ់ទឹក វិមានឯករាជ្យ បានជួបជាមួយជនសង្ស័យមានគ្នាពីរនាក់ ដោយជនសង្ស័យទាំងពីរនាក់នោះ បាននិយាយផ្តែផ្តាឱ្យសង្សារខ្លួន ពេលនោះសង្សារខ្លួនក៏ខឹង ហើយក៏ចូលទៅវាយគ្នាតែម្តង តែត្រូវខ្លួនចាប់ជាប់ តែអ្នកទាំងពីរនោះ នៅតែមិនព្រមឈប់និយាយឌឺដងសង្សារខ្លួនទៀត ។ ពេលនោះក៏មានការវាយគ្នាទៅវិញទៅមក ខ្លួនក៏បានស្រែកហៅឱ្យគេជួយ តែមិនមានអ្នកណាជួយនោះទេ ។ ខ្លួនអង្គុយយំ ស្រាប់តែពេលខ្លួនប្រឡេកទៅមើលសង្សារខ្លួនក៏ឃើញដួល ពេលនោះខ្លួនក៏រត់ទៅមើលមិនដឹងថាគាត់ស្លាប់ ឬអត់នោះទេ ។ ខ្លួនក៏ហៅឡានពេទ្យមកដឹកគាត់ទៅមន្ទីរពេទ្យ ។ ពេលទៅដល់មន្ទីរពេទ្យ គេប្រាប់ថាគាត់ស្លាប់បាត់ហើយ ។ លុះក្រោយមកខ្លួនក៏ពិនិត្យឃើញមានស្នាមហូរឈាមចេញពីក្រោមដោះខាងឆ្វេង ។ ក្នុងចំណោមជនសង្ស័យទាំងពីរខ្លួនមិនដឹងថា អ្នកណាជាអ្នកចាក់លើសង្សារខ្លួននោះទេ ហើយក៏មិនដឹងថាមានឈ្មោះ អ្វីខ្លះដែរ តែខ្លួនចំណាំមុខបាន ។ ខ្លួនសំណូមពរឱ្យតុលាការផ្តន្ទាទោសជនទាំងពីរនាក់នេះ និងសុំសំណងជម្ងឺចិត្តចំនួន ម្ភៃលានរៀល ។

- តំណាងមហាអយ្យការសន្និដ្ឋានថា: បណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទឈ្មោះ [redacted] យី ធ្វើឡើងតាមកំណត់ច្បាប់ ។ សាលក្រមរបស់សាលាដំបូងសម្រេចលើឈ្មោះ [redacted] យី ពីបទឃាតកម្មនោះ គឺពុំត្រឹមត្រូវនោះទេ ។ ត្បិតជនជាប់ចោទឈ្មោះ [redacted] រតនា បានសារភាពថា ខ្លួនជាអ្នកចាក់ជនរងគ្រោះនឹងកាំបិត ហើយជនជាប់ចោទឈ្មោះ [redacted] យី បានគប់ដុំថ្មលើជនរងគ្រោះ ចម្លើយនេះស៊ីសង្វាក់ជាមួយចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] យី ។ អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] យី ដែលគប់ដុំថ្មនោះ ជាអំពើហិង្សាចេតនាមានស្ថានទម្ងន់ទោសដែលត្រូវផ្តន្ទាទោសតាមមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ។ ដូច្នេះ គប្បីកែប្រែបទចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] យី ។ តំណាងមហាអយ្យការ សុំឱ្យក្រុមប្រឹក្សាពិចារណា និងសម្រេចឡើងវិញត្រង់ចំណុចនេះ ។

- លោក [redacted] ចន្ថា មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានសន្និដ្ឋានថា: មូលហេតុដែលប្តឹងឧទ្ធរណ៍នេះ គឺកូនក្តីខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ គឺឈ្មោះ [redacted] រតនា ហៅ មករា ជាអ្នកចាក់សម្លាប់ជនរងគ្រោះ ។ កូនក្តីខ្លួន ពិតជាបានរួមចំណែកក្នុងជម្លោះនេះ តែកូនក្តីខ្លួនមិនបានសម្លាប់ជនរងគ្រោះទេ គ្រាន់តែបានយកដុំថ្មគប់ទៅលើជនរងគ្រោះប៉ុណ្ណោះ ។ តាមការពិត គឺឈ្មោះ [redacted] រតនា ទើបជាអ្នកចាក់សម្លាប់ជនរងគ្រោះពិតប្រាកដ ។ ក្នុងរឿងនេះ គឺជនរងគ្រោះក៏បានយកខ្សែក្រវ៉ាត់វាយលើកូនក្តីខ្លួនដែរ ដូច្នេះខ្លួនសំណូមពរឱ្យ ក្រុមប្រឹក្សាមេត្តា បន្ធូបន្ថយទោសឱ្យកូនក្តីខ្លួនដោយក្តីអនុគ្រោះ ។

១៩១

- ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] យី

- ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] រតនា

- ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] វល័ក្ខ

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

- ក្រោយពីបានពិចារណាលើគ្រប់ភស្តុតាង និងឯកសារផ្សេងៗ

- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

សំអាងហេតុ

យល់ឃើញថា

១- ពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៩-០៧-២០១២ របស់ជនជាប់ចោទឈ្មោះ [redacted] យី ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៤៩ កបព "ទ" ចុះថ្ងៃទី១១-០៦-២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់សេចក្តីសម្រេចទាំងមូល ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ សាលាឧទ្ធរណ៍អាចទទួលជំនុំជម្រះបាន ។

២- តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] យី បានឆ្លើយថា: ខ្លួនមិនបានចាក់សម្លាប់ជនរងគ្រោះទេខ្លួនគ្រាន់តែបានយកដុំថ្មគប់ទៅលើជនរងគ្រោះតែប៉ុណ្ណោះ ។ ចម្លើយនេះ ស៊ីសង្វាក់ជាមួយជនជាប់ចោទឈ្មោះ [redacted] រតនា បានឆ្លើយថា ពេលនោះជនរងគ្រោះ ក៏បានបាក់ផាក់ឈ្មោះ [redacted] យី ហើយឈ្មោះ [redacted] យី ក៏ខឹងក៏រើសដុំថ្មគប់ទៅលើជនរងគ្រោះ មួយដុំត្រូវចំខ្លួន ពេលនោះជនរងគ្រោះក៏បានហូតខ្សែក្រវ៉ាត់ ចេញពីចង្កេះស្ទុះមកវ៉ៃពួកខ្លួន ចំណែកខ្លួនដៃកាន់កូនកាំបិតក៏ ចាក់សម្លាប់ជនរងគ្រោះ ។

-ក្រុមប្រឹក្សាយល់ថា ជនជាប់ចោទឈ្មោះ [redacted] យី មិនបានសម្លាប់ជនរងគ្រោះនោះទេ ។ ជាក់ស្តែងជនជាប់ចោទរូបនេះ គឺគ្រាន់តែយកដុំថ្ម គប់ទៅលើជនរងគ្រោះតែប៉ុណ្ណោះ ។ ក្រុមប្រឹក្សាយល់ថា អំពើល្មើសខាងលើនេះ បង្កឡើងដោយជនជាប់ចោទពីរនាក់ឈ្មោះ [redacted] រតនា និង [redacted] យី ដែលបានចូលរួមប្រព្រឹត្តបទល្មើស តែទង្វើរបស់ជនជាប់ចោទឈ្មោះ [redacted] យី គឺគ្រាន់តែយកដុំថ្មគប់ទៅលើជនរងគ្រោះតែប៉ុណ្ណោះ ដូច្នេះគប្បីក្រុមប្រឹក្សា សម្រេចផ្តន្ទាទោសដោយផ្អែកលើអំពើរបស់ជនជាប់ចោទឈ្មោះ [redacted] រតនា និង [redacted] យី ។

-ជនជាប់ចោទឈ្មោះ [redacted] រតនា បានសម្លាប់ជនរងគ្រោះ ដោយចាក់សម្លាប់នឹងកូនកាំបិត ក្រុមប្រឹក្សាយល់ថាជាបទឃាតកម្ម តាមមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ ។

- ជនជាប់ចោទឈ្មោះ [redacted] យី បានយកដុំថ្មគប់លើជនរងគ្រោះ តែមិនបានសម្លាប់ជនរងគ្រោះនោះទេ ។ ក្រុមប្រឹក្សាយល់ថា ជនជាប់ចោទរូបនេះ បានប្រព្រឹត្តអំពើហិង្សាមានស្ថានទម្ងន់ទោសយោងតាមមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ យោងតាមមាត្រា ២៤ នៃក្រមព្រហ្មទណ្ឌ ។

១៤៧

៣- សាលក្រមព្រហ្មទណ្ឌលេខ : ៤៩ កប៣ “ទ” ចុះថ្ងៃទី១១-០៦-២០១២ របស់សាលាដំបូងរាជធានីភ្នំពេញសម្រេចមានលក្ខណៈត្រឹមត្រូវហើយ លើកចំណុចដែលសម្រេចផ្ដន្ទាទោសជនជាប់ចោទឈ្មោះ [redacted] យី ពីបទឃាតកម្ម ដូច្នេះគប្បីក្រុមប្រឹក្សាពិចារណាកែប្រែបទចោទប្រកាន់លើជនជាប់ចោទរូបនេះ តាមការយល់ឃើញខាងលើ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្ដី

១- ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី០៩-០៧-២០១២ របស់ជនជាប់ចោទឈ្មោះ [redacted] យី ទុកត្រឹមត្រូវតាមទម្រង់ច្បាប់ និងគិតច្បាប់ខ្លះ ។

២- កែប្រែបទចោទប្រកាន់លើឈ្មោះ [redacted] យី ភេទប្រុស អាយុ២៩ឆ្នាំ ពីបទ ឃាតកម្ម តាមមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ មកជា បទ ហិង្សាមានស្ថានទម្ងន់ទោស តាមមាត្រា២១៨ នៃក្រមព្រហ្មទណ្ឌវិញ ។

៣- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ : ៤៩ កប៣ “ទ” ចុះថ្ងៃទី១១-០៦-២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល លើកលែងតែ ចំណុចទី១ នៃសេចក្ដីសម្រេចត្រង់ : “ផ្ដន្ទាទោសឈ្មោះ [redacted] យី ហៅ យី ភេទប្រុស ដាក់ពន្ធនាគារកំណត់រយៈពេល ១១ (ដប់មួយ)ឆ្នាំ ពីបទ ឃាតកម្ម ” *ត្រូវកែប្រែមកជា* “ផ្ដន្ទាទោសឈ្មោះ [redacted] យី ហៅ យី ភេទប្រុស ដាក់ពន្ធនាគារកំណត់ ៥ (ប្រាំ)ឆ្នាំ ពីបទ ហិង្សាមានស្ថានទម្ងន់ទោស តាមមាត្រា២១៨ នៃក្រមព្រហ្មទណ្ឌ ។

-ចំណុចក្រៅពីនេះ ត្រូវរក្សាទុកជាបានការដដែល ។

៤- បន្តឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] យី ហៅ យី តាមនីតិវិធីច្បាប់ ។

សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៨-០៩-២០១៤ កំបាំងមុខជនជាប់ចោទឈ្មោះ ទុំ យី និងចំពោះមុខមេធាវីការពារសិទ្ធិ ។

ទុកសិទ្ធិប្ដឹងទាស់ និងប្ដឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

សេចក្ដីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និងកងកម្លាំងប្រដាប់អាវុធ ជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
| --- | --- | --- |
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted], [redacted] | ហត្ថលេខា [redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

*រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែ ៥ ឆ្នាំ២០១៤*

ក្រឡាបញ្ជី

បានឃើញ

ប្រធានសាលាឧទ្ធរណ៍

[redacted]

១៥៣